**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ**...២០៩.....អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការរៀបចំ និងការប្រព្រឹត្តទៅ

## របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

*****

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១៥ ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្ការ និងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៦

# **សម្រេច**

## **ជំពូកទី ១**

## **បទប្បញ្ញត្តិទូទៅ**

**មាត្រា ១.-**

អនុក្រឹត្យនេះ កំណត់ការរៀបចំ បេសកកម្ម សមាសភាព រចនាសម្ព័ន្ធ និងមុខការនៃបណ្តាអង្គភាពនានា របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលសរសេរអក្សរកាត់ថា (**អ.ជ.ប.ជ.អ.**) ។

## **ជំពូកទី ២**

## **បេសកកម្ម សមាសភាព រចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ អ.ជ.ប.ជ.អ.**

**មាត្រា ២.-**

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជាស្ថាប័នជាតិមានលក្ខណៈជាពហុវិស័យ ដែលមានបេសកកម្ម ដឹកនាំ និង អនុវត្តការងារ បង្ការ និងការប្រយុទ្ធទប់ស្កាត់ ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ។

**មាត្រា ៣.-**

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍មានសមាសភាពដូចតទៅ ៖

| | | |
|---|---|---|
| ១- នាយករដ្ឋមន្ត្រី ឬសមាជិករាជរដ្ឋាភិបាល ០១ រូប | | ប្រធាន |
| ២- ឥស្សរជនជាន់ខ្ពស់ | ០១ រូប ឬ ច្រើនរូប | អនុប្រធាន |
| ៣- រដ្ឋលេខាធិការ | ទីស្តីការគណៈរដ្ឋមន្ត្រី ០១ រូប | សមាជិក |
| ៤- រដ្ឋលេខាធិការ | ០១ រូប នៃក្រសួងនានា | សមាជិក |
| ៥- អនុរដ្ឋលេខាធិការ | ០១រូប នៃរដ្ឋលេខាធិការដ្ឋាន | សមាជិក |
| ៦- អនុប្រធានទី១ សមាគមជាតិកាកបាទក្រហមកម្ពុជា | | សមាជិក |
| ៧- អភិបាលរងរាជធានីភ្នំពេញ ០១រូប | | សមាជិក |
| ៨- អភិបាល ឬអភិបាលរងខេត្ត ក្រុង ០១ រូបគ្រប់ខេត្ត ក្រុង | | សមាជិក |

សមាសភាពនៃ **អ.ជ.ប.ជ.អ.** ត្រូវកំណត់ដោយ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

## មាត្រា ៤._

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានមុខងារ និងភារកិច្ច ដូចតទៅ ៖

- លើកគោលនយោបាយជាតិប្រយុទ្ធនឹងជំងឺអេដស៍ ជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច
- លើកផែនការយុទ្ធសាស្ត្រ សម្រាប់អនុវត្តគោលនយោបាយជាតិជូនរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច
- លើកយោបល់ជូនរាជរដ្ឋាភិបាល អំពីបញ្ហាទាំងឡាយណា ដែលទាក់ទងនឹងស្ថានភាពជំងឺអេដស៍
- សម្របសម្រួល និងដឹកនាំអនុវត្តច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- សម្របសម្រួល ណែនាំ និងបង្កលក្ខណៈ អនុវត្តកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ នៅតាមក្រសួង ស្ថាប័ន ពាក់ព័ន្ធនានា អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងក្រុមហ៊ុនឯកជន ឱ្យមាននិរន្តរភាព
- ផ្សព្វផ្សាយច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍
- ស្វែងរកជំនួយពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដើម្បីគាំទ្រការអនុវត្តផែនការជាតិប្រយុទ្ធនឹងជំងឺអេដស៍
- ផ្លាស់ប្តូរបច្ចេកទេស និងបទពិសោធន៍ជាមួយប្រទេសទាំងឡាយ ដែលមានបញ្ហាអេដស៍
- ទ្រទ្រង់ សម្របសម្រួល និងសហការធ្វើការងារស្រាវជ្រាវអេពីដេមីសាស្ត្រ និងស្រាវជ្រាវផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច សង្គម
- ផ្តល់យោបល់ ណែនាំស្តីពីវិធានការ ដែលមានចែងក្នុងច្បាប់ស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរីករាលដាលមេរោគអេដស៍/ជំងឺអេដស៍ ដល់មន្ទីរពិសោធន៍ មន្ទីរពេទ្យនិងកន្លែងថែទាំព្យាបាលអ្នកផ្ទុកមេរោគអេដស៍/អ្នកជំងឺអេដស៍
- ពិនិត្យអនុម័តលើគម្រោងកម្មវិធីអប់រំ ដែលត្រូវធ្វើការផ្សព្វផ្សាយនៅតាម ក្រសួង ស្ថាប័ន សាលារៀន តាមវិទ្យុ ទូរទស្សន៍ កាសែត ទស្សនាវដ្តី និងលើកម្មវិធីអប់រំដោយផ្ទាល់
- ទទួលខុសត្រូវរៀបចំច្បាប់ និងចេញលិខិតបទដ្ឋានទាំងឡាយ ស្តីពីការត្រួតពិនិត្យ និងការអនុវត្តបទប្បញ្ញត្តិផ្សេងៗ ដែលទាក់ទងនឹងជំងឺអេដស៍ ដោយសង្កត់ធ្ងន់លើវិស័យសិទ្ធិមនុស្ស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន។

## មាត្រា ៥._

ប្រធាន **អ.ជ.ប.ជ.អ.** មានភារកិច្ចដូចតទៅ ៖

- សម្របសម្រួលជាពហុវិស័យ ដើម្បីឱ្យសមស្របនឹងការវិវត្តនៃការរីករាលដាលនៃមេរោគអេដស៍/ជំងឺអេដស៍
- ដឹកនាំគ្រប់គ្រងនិងចាត់ចែងការងារទូទៅ នៃ **អ.ជ.ប.ជ.អ.**

- ដឹកនាំកិច្ចប្រជុំពិភាក្សាពេញអង្គនៃ **អ.ជ.ប.ជ.អ.** ។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចផ្ទេរសិទ្ធិជូនអនុប្រធាន ដើម្បីដឹកនាំកិច្ចប្រជុំពិភាក្សា នេះជំនួស
- ស្នើ និងដំឡើងថ្នាក់ ឬឋានន្តរសក្តិដល់បុគ្គលិកនៃ **អ.ជ.ប.ជ.អ.** និងដាក់វិន័យទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ **អ.ជ.ប.ជ.អ.** និងច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា សំដៅលើកកម្ពស់ប្រសិទ្ធភាព សមត្ថភាព និងការស្អាតស្អំ ក្នុងការធ្វើការងារឱ្យបានកម្រិតខ្ពស់
- ធ្វើរបាយការណ៍បូកសរុប រាល់សកម្មភាពការងាររបស់ **អ.ជ.ប.ជ.អ.** ជូនប្រមុខរាជរដ្ឋាភិបាល
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលរាជរដ្ឋាភិបាលប្រគល់ជូន ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានទីប្រឹក្សាមួយចំនួន ដើម្បីជួយការងារ ។

អនុប្រធាន និងទីប្រឹក្សាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ហើយបំពេញភារកិច្ច តាមភារកិច្ចដែលប្រធានប្រគល់ជូន។

## មាត្រា ៦.-

**អ.ជ.ប.ជ.អ.** ត្រូវបើកសម័យប្រជុំពេញអង្គរបស់ខ្លួនយ៉ាងតិចពីរ (២) ដងក្នុងមួយឆ្នាំ ក្រោមអធិបតីភាព របស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានមួយរូប ត្រូវដឹកនាំសម័យប្រជុំជំនួស។ តាមការចាំបាច់ប្រធាន អាចអញ្ជើញតំណាងសហគមន៍ អ្នកផ្តល់ជំនួយចូលរួមប្រជុំជាអ្នកសង្កេតការណ៍ ។

## មាត្រា ៧.-

ក្នុងការបំពេញបេសកកម្ម **អ.ជ.ប.ជ.អ.** មានសិទ្ធិចេញបទដ្ឋានផ្សេងៗ ក្នុងវិស័យប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានលក្ខណៈជាវិធានទូទៅក្តី ជាបុគ្គលក្តី ដែលអាជ្ញាធរគ្រប់ជាន់ថ្នាក់ ត្រូវយកទៅអនុវត្តឱ្យមានប្រសិទ្ធភាព។

## មាត្រា ៨.-

**អ.ជ.ប.ជ.អ.** មានសិទ្ធិប្រើប្រាស់ត្រាផ្ទាល់របស់ខ្លួន ។

## មាត្រា ៩.-

**អ.ជ.ប.ជ.អ.** មានរចនាសម្ព័ន្ធដូចតទៅ ៖

- ខុទ្ទកាល័យប្រធាន **អ.ជ.ប.ជ.អ.**
- អគ្គលេខាធិការដ្ឋាន
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ក្រសួង ស្ថាប័ន
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ខេត្ត ក្រុង
- គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ ស្រុក ខណ្ឌ